**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ: ៣០៤៦ មស.ត្រ

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**គោរពជូន**
**ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**កម្មវត្ថុ** : ស្តីពីការផ្តល់យោបល់លើសំណើសុំរក្សាប្រាក់បៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់និងទទួលសោធននិវត្តន៍ នៅអង្គភាពដើមរបស់មន្ត្រីរាជការដែលជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**យោង** :-អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- យោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចំពោះការរក្សាទុកប្រាក់បំណាច់មុខងារសម្រាប់មន្ត្រីរាជការដែលត្រូវបានអនុញ្ញាតឱ្យទៅបម្រើការងារជាមន្ត្រីកិច្ចសន្យានៅគ.ជ.ប។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថាផ្អែកលើការសម្រេចរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មន្ត្រីរាជការដែលទទួលបានការអនុញ្ញាតពីក្រសួង ស្ថាប័ន ឱ្យទៅបម្រើការងារជាមន្ត្រីកិច្ចសន្យានៅគ.ជ.ប ត្រូវបានអនុញ្ញាតឱ្យរក្សាទុកបៀវត្សរួមមានបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ ព្រមទាំងអត្ថប្រយោជន៍ផ្សេងទៀត អនុលោមបទប្បញ្ញត្តិជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបតាមការគួរ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ពេជ្រ ប៊ុនធិន**

**<u>ចម្លងជូន៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី «ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh